# សំណួរអំពីការចុះឈ្មោះជាអ្នកបោះឆ្នោត

***តើអ្នកណាខ្លះអាចចុះឈ្មោះដើម្បីបោះឆ្នោត?/តើខ្ញុំអាចចុះឈ្មោះបោះឆ្នោតបាននៅពេលណា?***

មនុស្សដែលមានសិទ្ធិចុះឈ្មោះដើម្បីបោះឆ្នោត ត្រូវតែមានសញ្ជាតិសហរដ្ឋ ជាអ្នកមានលំនៅរដ្ឋកាលីហ្វ័រញ៉ា មិនជាប់គុក មិនឋិតក្នុងស្ថានភាពដោះចេញពីគុកដោយលក្ខខ័ណ្ឌ ដោយប្រព្រឹត្តបទឧក្រិដ្ឋ ហើយត្រូវមានអាយុយ៉ាងហោចណាស់ 18 ឆ្នាំ នៅពេលបោះឆ្នោត (ក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា កណ្ឌទី 2101)។

***តើការចុះឈ្មោះចប់ពេលណា?***

បុគ្គលម្នាក់ត្រូវតែចុះឈ្មោះឱ្យទាន់ 15 ថ្ងៃមុនថ្ងៃបោះឆ្នោត ដើម្បីបោះឆ្នោតនៅក្នុងការបោះឆ្នោតណាមួយ។

***តើខ្ញុំអាចចុះឈ្មោះដើម្បីបោះឆ្នោតយ៉ាងដូចម្តេច?/តើខ្ញុំអាចរកទំរង់បែបបទចុះឈ្មោះបោះឆ្នោតនៅឯណា?***

លោកអ្នកអាចចុះឈ្មោះដោយបំពេញទំរង់បែបបទចុះឈ្មោះបោះឆ្នោត ដែលមានផ្តល់ជូននៅក្នុងការិយាល័យរដ្ឋាភិបាលភាគច្រើន រួមទាំងសាលាក្រុង បណ្ណាល័យ DMV និងប៉ុស្តិ៍ប្រៃសណីយ៍ ឬតាមអ៊ិនធឺណិតនៅឯ http://www.ss.ca.gov/។ លោកអ្នកក៏អាចទាក់ទងជាមួយនាយកដ្ឋានស្មៀនក្រុង នៅលេខ (562) 570-6101 ហើយស្នើសុំឱ្យផ្ញើទំរង់បែបបទចុះឈ្មោះបោះឆ្នោតទៅលោកអ្នកក៏បាន។

***តើខ្ញុំអាចចុះឈ្មោះបោះឆ្នោតដោយប្រើអាស័យដ្ឋានអាជីវកម្មរបស់ខ្ញុំ ឬប្រអប់ប្រៃសណីយ៍បានទេ?***

មិនបានទេ។ បុគ្គលម្នាក់អាចចុះឈ្មោះបោះឆ្នោតបានតែនៅឯទីលំនៅរបស់គាត់ប៉ុណ្ណោះ។ អាស័យដ្ឋានអាជីវកម្ម ឬលេខប្រអប់ប្រៃសណីយ៍ អាចប្រើជាអាស័យដ្ឋានទទួលសំបុត្រតែប៉ុណ្ណោះ។

***តើខ្ញុំចាំបាច់ចុះឈ្មោះម្តងទៀតសំរាប់ការបោះឆ្នោតនីមួយៗទេ?/តើខ្ញុំត្រូវចុះឈ្មោះនៅពេលណាខ្លះ?***

លោកអ្នកមានឈ្មោះជាអ្នកបោះឆ្នោត ដរាបណាលោកអ្នករក្សាទុកអាស័យដ្ឋានដដែល ហើយលោកអ្នកនឹងបន្តទទួលឯកសារស្តីអំពីការបោះឆ្នោតតាមប្រៃសណីយ៍។ ក៏ប៉ុន្តែ បើលោកអ្នករើផ្ទះទៅអាស័យដ្ឋានថ្មី ឬមិនបានបោះឆ្នោត នៅក្នុងការបោះឆ្នោតប៉ុន្មានកន្លងទៅនេះ លោកអ្នកប្រហែលនឹងទទួលលិខិតមួយ សូមឱ្យលោកអ្នកបញ្ជាក់ថា លោកអ្នកមិនបានរើផ្ទះ ឬឱ្យលោកអ្នកផ្តល់ពតិមានអំពីអាស័យដ្ឋានទីលំនៅដ៏ទាន់សម័យ។ ការចុះឈ្មោះរបស់លោកអ្នកអាចត្រូវបានលុបចោល បើលោកអ្នកមិនឆ្លើយតបនឹងលិខិតស្នើសុំបញ្ជាក់អាស័យដ្ឋានទេ។ លោកអ្នកត្រូវតែចុះឈ្មោះម្តងទៀតនៅពេលដែលរើផ្ទះ ប្តូរឈ្មោះ ឬចង់ដូរគណៈបក្ស។

***តើធ្វើដូចម្តេច ដើម្បីឱ្យដឹងថា ខ្ញុំនៅមានឈ្មោះជាអ្នកបោះឆ្នោត ឬក៏អត់?***

សូមទាក់ទងជាមួយនាយកដ្ឋានស្មៀនក្រុងនៅលេខ (562) 570-6101 ដើម្បីសូមពត៌មានអំពីការចុះឈ្មោះបោះឆ្នោត។

***ខ្ញុំទើបតែរើផ្ទះ ហើយមិនបានចុះឈ្មោះម្តងទៀតទេ។ តើខ្ញុំមានសិទ្ធិបោះឆ្នោតទេ?***

បើលោកអ្នកបានចុះឈ្មោះបោះឆ្នោតពីមុន នៅក្នុងទីក្រុងឡុងប៊ីច ហើយបានរើផ្ទះនៅក្នុងព្រំដែនទីក្រុង លោកអ្នកអាចបោះឆ្នោតនៅឯទីកន្លែងបោះឆ្នោតសំរាប់អាស័យដ្ឋានថ្មីរបស់លោកអ្នក។ លោកអ្នកត្រូវយកប័ណ្ណបើកបរ ឬប័ណ្ណសំគាល់ខ្លួនរដ្ឋកាលីហ្វ័រញ៉ា ដែលមានអាស័យដ្ឋានបច្ចុប្បន្នរបស់លោកអ្នក។

***តើសាធារណៈជនអាចមើលពត៌មាន ដែលខ្ញុំបានផ្តល់នៅលើទំរង់បែបបទចុះឈ្មោះបោះឆ្នោតរបស់ខ្ញុំ បានឬទេ?***

ពត៌មានដែលទាក់ទងនឹងការចុះឈ្មោះបោះឆ្នោត មានផ្តល់ជូនឱ្យសាធារណៈជនមើលតាមសេរី (លើកលែងតែលេខសំគាល់ពិសេស ដូចជាលេខប័ណ្ណបើកបរ/ប័ណ្ណសំគាល់ខ្លួនរដ្ឋកាលីហ្វ័រញ៉ា លេខសន្តិសុខសង្គម [លេខសូសាល់] ។ល។) ស្របនឹងក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា កណ្ឌទី 2194 លើកលែងតែជនណាដែលមានលក្ខណៈសមស្របដើម្បីទទួលឋានៈសំងាត់ ស្របនឹងក្រមបោះឆ្នោតរដ្ឋកាលីហ្វ័រញ៉ា កណ្ឌទី 2166។